ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
ក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធ
ព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

# ព័ត៌មានបច្ចុប្បន្នភាពអំពីការអនុវត្តគម្រោង FMIS

ថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ២០១៥

## នាយករដ្ឋមន្ត្រី

“កែទម្រង់គឺរស់ មិនកែទម្រង់គឺស្លាប់! ការបំពាក់ស្មារតីអំពីភាពចាំបាច់ និងភាពបន្ទាន់នៃការកែទម្រង់ គឺជាកិច្ចការមិនអាចខ្វះបានសម្រាប់ថ្នាក់ដឹកនាំ និងមន្ត្រីគ្រប់ជាន់ថ្នាក់”។

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៥




## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

“ក្នុងន័យនេះ ខ្ញុំសូមស្នើឱ្យគ្រប់អ្នកពាក់ព័ន្ធទាំងអស់យកចិត្តទុកដាក់ និងជួយជំរុញការងាររៀងៗខ្លួនឱ្យឆ្ពោះទៅមុខ ដើម្បីធានាថាប្រព័ន្ធ FMIS នេះ នឹងអនុវត្តទៅបានទាន់ពេលវេលា”។

**ឯកឧត្តមបណ្ឌិត អូន ព័ន្ធមុនីរ័ត្ន**
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជា
ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៥

បន្ទាប់ពីឆ្លងកាត់ដំណាក់កាលវិភាគ, រៀបចំ, និងកសាង អស់រយៈពេល ១៨ ខែកន្លងផុតទៅ ប្រព័ន្ធ FMIS របស់យើងនឹងចាប់ផ្តើមដាក់ឱ្យអនុវត្តជាផ្លូវការនៅក្នុងរយៈពេល ៣ សប្តាហ៍ទៀត! ប្រព័ន្ធនេះនឹងអនុវត្តយ៉ាងពិតប្រាកដ។ ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ FMIS ជាផ្លូវការអាចប្រព្រឹត្តទៅបានតាមផែនការប្រកបដោយភាពស័ក្តិសិទ្ធិ លុះត្រាតែមន្ត្រីពាក់ព័ន្ធគន្លឹះមានភាពជាម្ចាស់ និង គាំទ្រពេញទំហឹងដល់ការដាក់ឱ្យប្រើប្រាស់នេះ។ ប្រព័ន្ធនេះនឹងបានជាប្រយោជន៍ដល់យើងគ្រប់គ្នា។ យើងនឹងក្លាយជាអ្នកប្រើប្រាស់ប្រព័ន្ធនេះគ្រប់ៗគ្នាតាមរយៈការប្រើប្រាស់ដោយផ្ទាល់ និងដោយប្រយោល។ **សម្រាប់មន្ត្រីជាអ្នកប្រើប្រាស់ប្រព័ន្ធ FMIS ផ្ទាល់** សូមត្រៀមខ្លួនសម្រាប់ការអនុវត្តប្រព័ន្ធ FMIS ហើយសម្រាប់ការត្រៀមខ្លួននេះ មន្ត្រីជាអ្នកប្រើប្រាស់ប្រព័ន្ធផ្ទាល់នឹងទទួលបាននូវការបណ្តុះបណ្តាល និងមានសមត្ថភាពពេញលេញ និងគ្រប់ជ្រុងជ្រោយមុនពេលដាក់ឱ្យប្រើប្រាស់ប្រព័ន្ធទៅតាមដំណាក់កាលដែលបានគ្រោងទុក។ មន្ត្រីពាក់ព័ន្ធទាំងអស់នេះ ត្រូវបានលើកទឹកចិត្តឱ្យផ្តល់នូវមតិឆ្លើយតប ឬ មតិយោបល់ ដើម្បីធានាថាការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធជាផ្លូវការនឹងមានដំណើរការរលូនទៅតាមគ្រប់មធ្យោបាយទំនាក់ទំនង និងផ្លាស់ប្តូរព័ត៌មាន។ **សម្រាប់មន្ត្រីមិនមែនជាអ្នកប្រើប្រាស់ប្រព័ន្ធ FMIS ផ្ទាល់** ត្រូវបានលើកទឹកចិត្តឱ្យស្វែងរកព័ត៌មានអំពីការអនុវត្តគម្រោង FMIS តាមដែលអាចធ្វើទៅបានតាមរយៈការអានអត្ថបទនេះ, ការចូលទៅកាន់គេហទំព័រគម្រោង FMIS, ឬ ទំនាក់ទំនងមកសមាជិកនៃក្រុមការងារគ្រប់គ្រងគម្រោង FMIS (FMWG) នៅក្នុងអគ្គនាយកដ្ឋាន-នាយកដ្ឋានសាមីនៅពេលដែលមានចម្ងល់ ឬ មតិយោបល់ផ្សេងៗចំពោះការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ FMIS ជាផ្លូវការ។

### ដំណាក់កាល និងសកម្មភាពសម្រាប់អនុវត្តប្រព័ន្ធ FMIS

- **ដំណាក់កាលទី ១**÷ ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៥ - មុខងារសៀវភៅធំ (GL) និងវិភាជន៍ថវិកា (BA)-ការគ្រប់គ្រងថវិកា និងរបាយការណ៍ហិរញ្ញវត្ថុ÷
    - ទាញយកទិន្នន័យដើម (សម្រាប់ថ្នាក់កណ្តាល) ចេញពីអគ្គនាយកដ្ឋានរតនាគារជាតិសម្រាប់សមតុល្យដើមគ្រា នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៥។ បន្ទាប់មកទាញយកទិន្នន័យរៀងរាល់សប្តាហ៍រហូតទាល់តែដំណាក់កាលទី២ នៃការដាក់ឱ្យប្រើប្រាស់មុខងារដទៃទៀតរបស់ប្រព័ន្ធចាប់ផ្តើមដំណើរការ
    - ទាញយកទិន្នន័យសមតុល្យដើមគ្រា (សម្រាប់ថ្នាក់កណ្តាល) ចេញពីអគ្គនាយកដ្ឋានថវិកា (រួមមាននាយកដ្ឋានថវិកានីយកម្ម នាយកដ្ឋានវិនិយោគ និង នាយកដ្ឋានគ្រប់គ្រងបំណុលនិងសហប្រតិបត្តិការ) នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ ២០១៥
    - មានការកែតម្រូវ និងផ្ទេរថវិកា (សម្រាប់ថ្នាក់កណ្តាល) នៅពេលដែលមានតម្រូវការ ដូចនេះទិន្នន័យថវិកាគឺត្រូវបានធ្វើបច្ចុប្បន្នភាពគ្រប់ពេល
    - អាចផលិតរបាយការណ៍ហិរញ្ញវត្ថុជាប្រចាំពីប្រព័ន្ធ FMIS និង
    - មានអ្នកប្រើប្រាស់ប្រមាណជា ១៦ នាក់ ដែលមកពីនាយកដ្ឋានព័ត៌មានវិទ្យា អគ្គនាយកដ្ឋានរតនាគារជាតិ និងអគ្គនាយកដ្ឋានថវិកា។

- **ដំណាក់កាលទី២÷**ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៥ - មានមុខងារការទិញ (PO), គណនីត្រូវសង (AP), គណនីត្រូវទារ (AR), និងគ្រប់គ្រងសាច់ប្រាក់ (CM)-នីតិវិធីអនុវត្តការងារធំៗត្រូវអនុវត្តតាមប្រព័ន្ធ FMIS សម្រាប់ថ្នាក់កណ្តាលនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ហើយការធ្វើរបាយការណ៍នឹងមានព័ត៌មានបន្ថែមកាន់តែច្រើន និងឆាប់រហ័សជាងមុន÷
    - បញ្ឈប់ការទាញយកទិន្នន័យដើមពីប្រព័ន្ធព័ត៌មាននៃអគ្គនាយកដ្ឋានរតនាគារជាតិ
    - រាល់ទិន្នន័យនៅថ្នាក់កណ្តាលនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងត្រូវបញ្ចូលដោយ អគ្គនាយកដ្ឋានថវិកា (រួមមាននាយកដ្ឋានហិរញ្ញកិច្ច, នាយកដ្ឋានវិនិយោគ, និងនាយកដ្ឋានគ្រប់គ្រងបំណុលនិងសហប្រតិបត្តិការ) និងអគ្គនាយកដ្ឋានរតនាគារជាតិ (រួមមាននាយកដ្ឋានចំណូល-ចំណាយថវិកា និងនាយកដ្ឋានគណនេយ្យ)
    - ធ្វើសន្ធានកម្មជាមួយប្រព័ន្ធខាងក្រៅរួមមាន ប្រព័ន្ធធនាគារ, ប្រព័ន្ធបៀវត្ស, ប្រព័ន្ធ DMFAS, និងប្រព័ន្ធ ASYCUDA
    - ការត្រួតពិនិត្យថវិកាត្រូវដាក់ឱ្យដំណើរការនៅក្នុងប្រព័ន្ធ FMIS
    - ការកែតម្រូវ និងផ្ទេរថវិកា (សម្រាប់ថ្នាក់កណ្តាល) ត្រូវអនុវត្តបន្តរហូតនៅក្នុងប្រព័ន្ធ FMIS
    - រាល់ការទូទាត់ចំណាយនៅថ្នាក់កណ្តាលទាំងអស់ត្រូវអនុវត្តតាមប្រព័ន្ធ FMIS ដោយអគ្គនាយកដ្ឋានរតនាគារជាតិ
    - ការធ្វើរបាយការណ៍ចេញពីប្រព័ន្ធ FMIS នឹងកាន់តែធំទូលាយតាមការចង់បានរបស់អ្នកប្រើប្រាស់ប្រព័ន្ធ
    - ចំនួនអ្នកត្រូវប្រើប្រាស់ប្រព័ន្ធនឹងមានច្រើនជាង ១៥០ នាក់ ដើម្បីចុះប្រតិបត្តិការ, គ្រប់គ្រងថវិកា, និងធ្វើរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ថ្នាក់កណ្តាល។
- **ដំណាក់កាលទី៣÷** ខែមករា/កុម្ភៈ ឆ្នាំ២០១៦ - ដាក់ឱ្យប្រព័ន្ធ FMIS អនុវត្តនៅតាមរតនាគាររាជធានី-ខេត្តទាំងអស់÷
    - ជាដំណាក់កាលដាក់ឱ្យដំណើរការប្រព័ន្ធសម្រាប់រតនាគាររាជធានី-ខេត្តលើការទូទាត់ចំណាយ និងការធ្វើរបាយការណ៍
    - រាល់នីតិវិធី និង ប្រតិបត្តិការហិរញ្ញវត្ថុ និង ការអនុវត្តថវិកាសម្រាប់ឆ្នាំ ២០១៦ នឹងចាប់អនុវត្តតាមប្រព័ន្ធ FMIS ទាំងស្រុងនៅចុងខែកុម្ភៈ ឆ្នាំ ២០១៦ ដែលជាពេលបញ្ចប់នៃការអនុវត្តគម្រោង FMIS ដំណាក់កាលទី១។

- នឹងចាប់ផ្តើមអនុវត្តគម្រោង FMIS ដំណាក់កាលទី២ ដើម្បីបែងចែកការទទួលខុសត្រូវក្នុងការធ្វើប្រតិបត្តិការ និងការធ្វើរបាយការណ៍ទៅដល់ស្ថាប័នថ្នាក់កណ្តាល និងតាមបណ្តាខេត្ត ដោយរួមបញ្ចូលទាំងមុខងារបន្ថែមថ្មីរបស់ប្រព័ន្ធ FMIS ។

ប្រព័ន្ធ FMIS គឺជាស្នូល, ជាយន្តការគន្លឹះ, និងជាច្រកចេញរបស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ហើយការអនុវត្តគម្រោង FMIS ដំណាក់កាលទី ១ គឺជាមូលដ្ឋានគ្រឹះក្នុងការសម្រេចឱ្យបាននូវគោលដៅនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុនៅដំណាក់កាលបន្តរបស់កម្ពុជាប្រកបដោយប្រសិទ្ធភាព និង ភាពស័ក្តិសិទ្ធិក្នុងការគ្រប់គ្រង និង បែងចែកធនធានរបស់កម្ពុជា។ ប្រព័ន្ធនេះនឹងចូលរួមបង្កើននូវ សីលធម៌, ភាពវាងវៃ, វិន័យ, គណនេយ្យភាព, តម្លាភាព, សមត្ថភាព, សមធម៌, ប្រសិទ្ធភាព, និងគុណភាព នៃការផ្តល់សេវាសាធារណៈលើគ្រប់វិស័យនៅកម្ពុជា។ ចំណែកការអនុវត្តគម្រោង FMIS ដំណាក់កាលទី២ នឹងត្រូវរៀបចំផែនការក្នុងកំឡុងឆ្នាំ ២០១៥ ដោយបញ្ចូលនូវ

មុខងារសំខាន់ៗបន្ថែម ដូចជា ការគ្រប់គ្រប់ទ្រព្យសម្បត្តិរដ្ឋ, ការគ្រប់គ្រងកិច្ចសន្យា, និងលទ្ធកម្មសាធារណៈ, ការគ្រប់គ្រងសន្និធិ, និងការរៀបចំថវិកា ជាដើម។ ការអនុវត្តថវិកាកម្មវិធី និង ការបន្តពង្រឹងដំណើរការវិមជ្ឈការ និង វិសហមជ្ឈការរបស់រាជរដ្ឋាភិបាលកម្ពុជានឹងសម្រេចបានដោយរលូន, ទាន់សភាពការណ៍, និងមានលក្ខណៈជាប្រព័ន្ធ តាមរយៈការអនុវត្តប្រព័ន្ធ FMIS ពេញលេញ និងគ្របដណ្តប់។

## សេចក្តីលម្អិតពីដំណាក់កាល សកម្មភាព និងផលប៉ះពាល់នៃការអនុវត្តប្រព័ន្ធ FMIS

**ដំណាក់កាលទី១** នៃប្រព័ន្ធ FMIS នឹងត្រូវដាក់ឱ្យប្រើប្រាស់នៅក្នុងខែកក្កដា ឆ្នាំ២០១៥ ខាងមុខនេះ។ ការដាក់ឱ្យដំណើរការប្រព័ន្ធនេះត្រូវបានឆ្លងកាត់ការរៀបចំផែនការយ៉ាងយកចិត្តទុកដាក់បំផុត ដើម្បីឆ្លើយតបទៅនឹងការចង់បានរបស់ឯកឧត្តមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** ដែលចង់ឱ្យមាន "ការវិវឌ្ឍជាជាងបដិវត្ត"។ ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ FMIS ជាផ្លូវការត្រូវបានបែងចែកចេញជាបីដំណាក់កាលសម្រាប់ការអនុវត្តគម្រោង FMIS ដំណាក់កាលទី១។ សម្រាប់ដំណាក់កាលទី១ នៃការដាក់ប្រព័ន្ធ FMIS ឱ្យប្រើប្រាស់គឺ មុខងារសៀវភៅធំ (General Ledger) និងវិភាជន៍ថវិកា (Budget Allocation) នឹងត្រូវដាក់ឱ្យដំណើរការ។ មន្ត្រីនៃនាយកដ្ឋានព័ត៌មានវិទ្យាចំនួន៤រូប នឹងទទួលខុសត្រូវគ្រប់គ្រងលើការដាក់បញ្ចូលទិន្នន័យជាក់ស្តែងពីអគ្គនាយកដ្ឋានរតនាគារជាតិ និងសមតុល្យថវិកាដើមគ្រាទៅក្នុងប្រព័ន្ធ FMIS។ ជាមួយគ្នានេះ អ្នកប្រើប្រាស់៤រូប មកពីអគ្គនាយកដ្ឋានរតនាគារជាតិនឹងគ្រប់គ្រងទៅលើទិន្នន័យដែលបានដាក់បញ្ចូលរួចទៅក្នុងប្រព័ន្ធ FMIS ពិនិត្យកែសម្រួលឡើងវិញ និងបន្ទាប់មកបញ្ចូលទៅក្នុងបញ្ជីសៀវភៅធំ (Posting) សម្រាប់សមតុល្យដើមគ្រា រួចហើយអគ្គនាយកដ្ឋានរតនាគារជាតិនឹងបន្តធ្វើបច្ចុប្បន្នភាពលើទិន្នន័យជារៀងរាល់សប្តាហ៍។ ជាមួយគ្នានេះដែរ អ្នកប្រើប្រាស់៨រូបផ្សេងទៀតមកពីអគ្គនាយកដ្ឋានថវិកា នឹងត្រូវចូលរួមរៀបចំទិន្នន័យថវិកាសម្រាប់សមតុល្យដើមគ្រា រួចបន្តកត់ត្រារាល់ការកែសម្រួលទិន្នន័យថវិកាទាំងអស់នៅក្នុងប្រព័ន្ធ FMIS ទៅតាមការស្នើសុំ។ ចំពោះប្រតិបត្តិការដែលអនុវត្តដោយដៃ នឹងត្រូវអនុវត្តបន្តដដែលរួមជាមួយការអនុវត្តក្នុងប្រព័ន្ធ FMIS។ ប្រព័ន្ធ FMIS នឹងដាក់ឱ្យដំណើរការព្រមគ្នាជាមួយប្រព័ន្ធដទៃទៀត ប៉ុន្តែប្រព័ន្ធទាំងនោះនឹងបន្តប្រតិបត្តិការសម្រាប់រយៈពេលខ្លីតែប៉ុណ្ណោះ ដើម្បីធានាថាប្រព័ន្ធ FMIS មាននិរន្តរភាព និងអាចធ្វើការផ្ទៀងផ្ទាត់របាយការណ៍ជាមួយគ្នាបាន។

**សម្រាប់ដំណាក់កាលទី២** ដែលគ្រោងនឹងដាក់ឱ្យប្រើប្រាស់នៅ ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៥ នឹងរួមបញ្ចូលការដាក់ឱ្យដំណើរការលើមុខងារការទិញ (PO), គណនីត្រូវសង (AP), គណនីត្រូវទារ (AR), ការគ្រប់គ្រងសាច់ប្រាក់ (CM) ព្រមទាំងការធ្វើសន្ធានកម្មជាមួយប្រព័ន្ធខាងក្រៅ រួមមានប្រព័ន្ធ ASYCUDA (គយ), ប្រព័ន្ធប្រាក់បៀវត្ស (Payroll), ប្រព័ន្ធ DMFAS (បំណុល), ប្រព័ន្ធធនាគារអេស៊ីលីដា, ប្រព័ន្ធធនាគារកាណាឌីយ៉ា, និងប្រព័ន្ធធនាគារជាតិនៃកម្ពុជា។ អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ នឹងអនុវត្តលើមុខងារការទិញ (PO) ហើយនាយកដ្ឋានហិរញ្ញកិច្ច, នាយកដ្ឋានវិនិយោគ, និងនាយកដ្ឋានគ្រប់គ្រងបំណុលនិងសហប្រតិបត្តិការ នឹងអនុវត្តទៅលើមុខងារការទិញ (PO) និងមុខងារគណនីត្រូវសង (AP)។ អគ្គនាយកដ្ឋានរតនាគារជាតិ នឹងអនុវត្តទៅលើមុខងារគ្រប់គ្រងសាច់ប្រាក់ (CM) និងត្រូវចូលអនុវត្តលើមុខងារគណនីត្រូវសង (AP) ផងដែរ។ ដំណាក់កាលទី២នេះ នឹងបន្ថែមនូវអ្នកដែលប្រើប្រាស់ប្រព័ន្ធជាង ១០០នាក់ទៀត ហើយការទំនាក់ទំនងផ្សព្វផ្សាយ និងការបណ្តុះបណ្តាលអំពីមុខងារទាំងនេះ នឹងត្រូវចាប់ផ្តើមក្នុងខែកក្កដាខាងមុខ។ តាមរយៈដំណាក់កាលទី២នេះ រាល់ការទូទាត់ចំណាយទាំងអស់ត្រូវអនុវត្តតាមប្រព័ន្ធ FMIS។

**ចំណែកដំណាក់កាលទី៣** ដែលគ្រោងនឹងដាក់ឱ្យប្រើប្រាស់នៅក្នុងខែមករា និងកុម្ភៈ ឆ្នាំ២០១៦ ខាងមុខនេះ នឹងដាក់ប្រព័ន្ធឱ្យប្រើប្រាស់ជាផ្លូវការដល់គ្រប់រតនាគាររាជធានី-ខេត្ត ទៅតាមលំដាប់លំដោយ និងអនុវត្តឱ្យបានរហ័ស។ ដំណាក់កាល

ទី៣នេះ នឹងបន្ថែមនូវអ្នកដែលត្រូវប្រើប្រាស់ប្រព័ន្ធប្រមាណជា ១៣០ ទៅ ១៥០នាក់ទៀតនៅតាមរតនាគាររាជធានី-ខេត្ត។ នាយកដ្ឋានថវិកានីយកម្ម នឹងធ្វើការបញ្ចូលទិន្នន័យសមតុល្យថវិកាដើមគ្រាសម្រាប់ឆ្នាំ២០១៦ ក្នុងអំឡុងខែធ្នូ ឆ្នាំ ២០១៥ ហើយប្រព័ន្ធ FMIS នឹងចាប់អនុវត្តពេញលេញនៅខែមីនា ឆ្នាំ២០១៦។ មន្ត្រីនៅតាមបណ្តារតនាគារ រាជធានី-ខេត្តទាំងអស់ នឹងបញ្ចូលទិន្នន័យប្រតិបត្តិការដោយផ្ទាល់ទៅក្នុងប្រព័ន្ធ FMIS ដែលស្ថិតនៅថ្នាក់កណ្តាល ព្រមទាំងអាចផលិតរបាយការណ៍បានយ៉ាងងាយ។ ចំណែកប្រតិបត្តិការដែលធ្លាប់បញ្ចូលពីរ ឬបីដងដូចជានៅក្នុង Web Portal ឬ Excel នៅតាមរនាគាររាជធានី-ខេត្ត នឹងមិនចាំបាច់អនុវត្តបន្តទៀតឡើយ នៅពេលអនុវត្តតាមប្រព័ន្ធ FMIS ពេញលេញ។

**តើអ្វីទៅជាប្រព័ន្ធ** FMIS?

ប្រព័ន្ធ FMIS គឺជាធាតុដ៏សំខាន់នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ហើយប្រព័ន្ធនេះគឺជាមូលដ្ឋានគ្រឹះក្នុងការសម្រេចឱ្យបាននូវគណនេយ្យភាពហិរញ្ញវត្ថុនៅដំណាក់កាលទី២ នៃ PFMRP និងដំណើរឈានឆ្ពោះទៅមុខដោយរលូននៃ PFMRP នៅគ្រប់ដំណាក់កាល។ ប្រព័ន្ធនេះគឺជាប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរួមមួយដែលជួយឱ្យការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយភាពជឿទុកចិត្ត (គណនេយ្យភាព តម្លាភាព សង្គតិភាព និងប្រសិទ្ធភាព) និងផ្តល់នូវព័ត៌មានគ្រប់ជ្រុងជ្រោយសម្រាប់ការគ្រប់គ្រង ដោយអនុលោមទៅនីតិវិធីអនុវត្តការងារដែលមានលក្ខណៈស្តង់ដារ។ បច្ចេកវិទ្យាព័ត៌មានមានប្រយោជន៍យ៉ាងខ្លាំងក្នុងការបង្កើនល្បឿននីតិវិធីអនុវត្តការងារទាំងឡាយ, ជួយឱ្យការទំនាក់ទំនងមានភាពងាយស្រួល, និងផ្តល់លទ្ធភាពដល់អ្នកប្រើប្រាស់ដែលមានសិទ្ធិ អាចទាញយកទិន្នន័យ និងព័ត៌មានទាំងអស់ដែលមាននៅក្នុងប្រព័ន្ធ។ ការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយភាពជឿទុកចិត្ត គឺអាចធ្វើទៅបានដោយសារមានការត្រួតពិនិត្យថវិកា និងមូលនិធិដែលអាចប្រើប្រាស់បាននៅគ្រប់ដំណាក់កាលក្នុងពេលអនុវត្តការងារដូចជា ការធ្វើលទ្ធកម្ម និងការទូទាត់ចំណាយជាដើម។ ប្រព័ន្ធ FMIS ផ្តល់នូវប្រព័ន្ធត្រួតពិនិត្យសុវត្ថិភាពលើរាល់ប្រតិបត្តិការដែលបានអនុវត្ត និងអ្នកដែលអនុវត្តប្រតិបត្តិការនោះ ហើយក៏ផ្តល់នូវភស្តុតាងសម្រាប់ការធ្វើសវនកម្ម (Audit logs) លើគ្រប់ប្រតិបត្តិការផងដែរ។ ព័ត៌មានសម្រាប់ការគ្រប់គ្រងគឺរួមមានទាំងព័ត៌មានហិរញ្ញវត្ថុ មិនមែនហិរញ្ញវត្ថុ និងព័ត៌មានដែលផ្តល់លទ្ធភាពតាមដានលើរយៈពេលនៃដំណើរការនីតិវិធីអនុវត្តការងារខុសៗគ្នា។ សូចនាករស្ថិតិ និងសូចនាករសមិទ្ធកម្មការងារគន្លឹះដែលមានសារៈសំខាន់សម្រាប់ការអនុវត្តថវិកាកម្មវិធី គឺអាចគ្រប់គ្រងបាននៅក្នុងប្រព័ន្ធ FMIS។

**សូមអរគុណ**

សម្រាប់ព័ត៌មានបន្ថែមអំពីគម្រោង FMIS, លោកអ្នកអាចចូលទៅកាន់គេហទំព័រគម្រោង FMIS

www.fmis.mef.gov.kh ឬទំនាក់ទំនងមក

សហប្រធានក្រុមគ្រប់គ្រងការផ្លាស់ប្តូររបស់គម្រោង FMIS

លោក **ហ៊ីង បញ្ញាសិទ្ធិ** ☎ ទូរស័ព្ទ÷ **011 238 888** @ អ៊ីមែល÷ **h_panhaseth@yahoo.com**

លោក **ឈាង យូ** ☎ ទូរស័ព្ទ÷ **016 848 545** @ អ៊ីមែល÷ **chheang_you@mef.gov.kh**